

# ស្លួនដំបូល

Kim Ann Arun

Chea Sereyroth

Let's Read

The Asia Foundation



ថ្ងៃអាទិត្យ ទីតាទៅលេងសួនកន្លែងធ្វើការរបស់ឪពុក។ ពេលមកផ្ទះវិញ នាងយកផ្កាឈូករ័ត្នមួយបាច់មកតាំងនៅលើដំបូល។



មួយអាទិត្យ ផ្កាស្រពោន។ ទីតាក៏ក្រៀមក្រំ។ នាងចង់ឱ្យផ្ការីក
គ្រប់ពេល។ ទីតាក៏នឹកឃើញបង្កើតសួនមួយនៅលើដំបូល។



ថ្ងៃសៅរ៍នេះ ទីតាបបួលឪពុកបង្កើតសួន។ គាត់យកដីជី និង គ្រាប់ផ្កាមក។ ឃើញហើយ ទីតាក៏សួរ៖ «ដាំយ៉ាងម៉េច... ប៉ា?» ឪពុកញញឹមបបួលកូន៖ «តោះពួកយើងដាំវាជាមួយគ្នា!»



ពួកគេជ្រោយដី និងកាយស្មៅចេញពីដី។ ភ្លាមនោះទីតាស្រែក៖ «ជន្លេនៗ!» ឪពុកពន្យល់៖ «ដីមានជន្លេន គឺល្អសម្រាប់ការដាំដុះ។» នាងងក់ក្បាលទាំងខ្លាច តែនៅតែបន្តធ្វើ។



ពួកគេបន្តដាំ ។ រួចរាល់ ទីតាស្រោចទឹកឈូៗ៖ «ផឹកទឹកឱ្យឆ្អែតទៅ .... ហើយត្រូវតែឆាប់ដុះ!» ឪពុកឃាត់៖ «ពួកវាត្រូវការទឹក តែមិនមែនស្រោចបែបនេះទេ។»



ទីតាស្រោចតាមការណែនាំ តែមិនឃើញដើមផ្កាដុះសោះ។ ម្ដាយទះស្មាកូនថ្នមៗ ៖ «វាត្រូវការពេលដុះ ដូច្នេះកូនត្រូវអត់ធ្មត់។»





មួយអាទិត្យក្រោយ ពន្លកផ្កាតូចៗលូតធំ អាចបំបែកដាំផ្សេងពីគ្នា។ ម្ដាយជីកគាស់ដើមផ្កាថ្មម ទីតាក៏ស្រវាដកទាំងអស់តែម្ដង។ ឃើញហើយ ម្ដាយក៏ឃាត់៖ «ទេ ដកថ្មមៗ កុំឱ្យដាច់ឫស។ បើមិនអីចឹងផ្កាមិនអាចដុះទេ។» ទីតាភ្ញាក់ផ្អើល។ សំណាងល្អ មានផ្កាពីរដើមដែលម្ដាយទើបគាស់រួច។



ពួកគេក៏ដាំវាក្នុងផើងពីរផ្សេងគ្នា។ ឪពុកយកកំណាត់ឈើចាស់ៗមកវាយធ្វើផើងផ្កា។



ទីតាចេះមើលថែដើមផ្កាយ៉ាងល្អ។ ដើមនិងស្លឹកលូតលាស់ស្រស់បំព្រង។ ពន្លកផ្កាចេញព្រោងព្រាត។



នាងកាច់ផ្កាមកតាំង។ ក្រឡេកឃើញបន្លែនៅលើតុ ទីតា នឹកឃើញសួរ៖ «ម៉ាក់! របស់នេះអាចដាំបានដែរឬទេ?» ម្ដាយប្រាប់ថា «បាន។» បន្ទាប់មកពួកគេក៏យកវាទៅដាំ។



ទីតាបន្តដាំបន្លែផ្សេងទៀតដូចជាស្ពៃ ត្រកួន និងម្ទេស។ នាង
ក៏បានដាំផ្កាផ្សេងទៀតដែលឪពុកយកពូជពីកន្លែងធ្វើការមក។



ច្រើនខែកន្លង សួនដំបូលលេចរូបរាងឡើង។ ជាសួនដែលមាន ចាប និងកន្ទុំរុយមកលេង។ ជាសួនដែលអ្នកជិតខាងសរសើរ និងសួរពីរបៀបដាំ។ ជាសួនដែលគ្រួសារទីតាមើលផ្កា និងបេះបន្លែមកធ្វើម្ហូប។



Generously supported by SMART

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org


**Original Story**

*សួនដំបូល (Rooftop Garden)*, Author: Kim Ann Arun. Illustrator: Chea Sereyroth. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.



This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/